ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងស្រុបទោស

លេខ: ២៤៤

ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩

សាលដីកាស្រុបទោស

លេខ: ៣៥ VIII

ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា
# តាងនាមប្រជារាស្ត្រខ្មែរ
# តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន

២.លោក [redacted] ចៅក្រម (របាយការណ៍)

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោក [redacted] ចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ២៥៥ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩ របស់លោក [redacted] ចន្ថា ជាមេធាវីការពារឱ្យទណ្ឌិតឈ្មោះ [redacted] ទិត ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១០ "ក្រ.VII.ភស" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ដែលមាន៖

- -ទណ្ឌិតឈ្មោះ [redacted] ទិត ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរលាងម៉ូតូ មានទីកន្លែងកំណើត និង



Scanned with CamScanner

[redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ទោសពីមុនគ្មាន ។ បច្ចុប្បន្នកំពុងជាប់ឃុំខ្លួននៅពន្ធនាគារ ខេត្តកំពង់ឆ្នាំង ។ (អ្នកប្តឹងសាទុក្ខ)

-មានមេធាវីការពារសិទ្ធិលោក [redacted]ចន្ថា ។

កម្មវត្ថុ: ប្តឹងសុំអនុវត្តស្រូបទោសបញ្ចូលគ្នា ។

តាមពាក្យសុំឱ្យស្រូបទោសបញ្ចូលគ្នា ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] រិត បានបញ្ជាក់ថា: ខ្លួនមានសំណុំរឿងព្រហ្មទណ្ឌ ចំនួន ០២ករណី ដែលមានសាលដីកាព្រហ្មទណ្ឌលេខ ២៧ ក្រV "វ" ចុះថ្ងៃ២៤ ខែមេសា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ បានចូលជាស្ថាពរ និងសាលក្រមលេខ ៤០ "ឃ" ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង បានចូលជាស្ថាពរទាំងអស់រួចហើយ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ៤០ "ឃ" ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ដែលបានសម្រេចផ្តន្ទាទោសលើឈ្មោះ [redacted] រិត ភេទប្រុស អាយុ៥៣ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ ពីបទ: ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ មាត្រា ៤៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ៥៨ "ខ" ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ដែលបានសម្រេចផ្តន្ទាទោសលើឈ្មោះ [redacted] រិត ភេទប្រុស អាយុ ៥៣ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ពីបទ: រក្សាទុក ចែកចាយ ប្រើប្រាស់ និងផ្តល់ទីតាំងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ មាត្រា ៤៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌស្ថាពរលេខ ២៧ ក្រV "វ" ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥៨ "ខ" ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង លើកលែងតែចំណុចទី ១-ខ ត្រង់ "ផ្តន្ទាទោសឈ្មោះ [redacted] រិត ភេទប្រុស អាយុ ៥៣ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៣ (បី) ឆ្នាំ" ត្រូវកែប្រែមកជា "ផ្តន្ទាទោសឈ្មោះ [redacted] រិត ភេទប្រុស អាយុ៥៣ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៣ (បី) ឆ្នាំ តែទោសនេះអនុវត្តទោសពន្ធនាគារ ១ឆ្នាំ ៦ខែ (មួយឆ្នាំប្រាំមួយខែ) ទោសសល់ពីនេះអនុវត្តទោសព្យួរធម្មតា" ។

-បានឃើញ ពាក្យសុំស្រូបទោសបញ្ចូលគ្នា ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] រិត ។

Scanned with CamScanner

-បានឃើញ សាលដីកាលេខ ១០ “ក្រ.VII.ភស” ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច៖

១-បដិសេធចោលពាក្យសុំឱ្យស្រូបទោសបញ្ចូលគ្នា ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] រិត ជាអសារបង់ ។

២-សាលដីកានេះ ប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ។

ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ២៥៥ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩ របស់លោក [redacted] ចន្ថា មេធាវីការពារឱ្យទណ្ឌិតឈ្មោះ [redacted] រិត ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១០ “ក្រ.VII.ភស” ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា៖

-យល់ឃើញថា ទណ្ឌិតសុំប្តឹងស្រូបទោសៈ

-សាលក្រមព្រហ្មទណ្ឌលេខ ៤០ “ឃ” ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ ពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

-សាលក្រមព្រហ្មទណ្ឌលេខ៥៨ “ខ” ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ ដាក់ពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ ពីបទៈ រក្សាទុក ចែកចាយ ប្រើប្រាស់ និងផ្តល់ទីតាំងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។ តែសាលដីកាសាលាឧទ្ធរណ៍បានតែមកផ្តន្ទាទោស ០១ឆ្នាំ ០៦ខែ (មួយឆ្នាំប្រាំមួយខែ) វិញ ។

តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖

១-បណ្តឹងសាទុក្ខលេខ ២៥៥ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩ របស់លោក [redacted] ចន្ថា ជាមេធាវីការពារសិទ្ធិឱ្យទណ្ឌិតឈ្មោះ [redacted] រិត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយខុសទៅនឹងគតិច្បាប់ ។

២-បដិសេធពាក្យសុំស្រូបទោសបញ្ចូលគ្នា ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] រិត ចោលជាអសារបង់ ។

+ទណ្ឌិតឈ្មោះ [redacted] រិត បានឆ្លើយថា៖ ខ្ញុំបាទបានដឹងកំហុសហើយ សុំតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្ញុំបាទផង ។

+លោក [redacted] ចន្ថា ជាមេធាវីការពារបានធ្វើសេចក្តីសន្និដ្ឋានថា៖ មូលហេតុដែលកូនក្តីខ្ញុំបាទប្តឹងសាទុក្ខមកនេះគឺដើម្បីសុំស្រូបទោសបញ្ចូលគ្នា ដោយសុំបន្ថយពី ៣ឆ្នាំ ៦ខែ មកនៅត្រឹម ២ឆ្នាំ ៦ខែ វិញ ដោយហេតុ



Scanned with CamScanner

ថា រយៈពេលដែលកូនក្តីខ្ញុំបាទនៅក្នុងពន្ធនាគារកន្លងមក គាត់មានការភ្ញាក់រឮក និងដឹងនូវកំហុសរបស់ខ្លួន ។ តាមការបញ្ជាក់របស់ប្រធានពន្ធនាគារថា ទណ្ឌិតរូបនេះបានកែប្រែខ្លួនយ៉ាងល្អ ព្រមទាំងជួយធ្វើការងារនៅក្នុងពន្ធនាគារជាច្រើនទៀតផង ។

សំណូមពរៈ សុំតុលាការមេត្តាសម្រេចធ្វើការស្រូបទោសមួយផ្នែកដល់កូនក្តីខ្ញុំបាទ ។ -

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ទណ្ឌិតឈ្មោះ [redacted] រិត

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឱ្យទណ្ឌិត

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៥៥ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] រិត ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៦៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន ។

២-យល់ឃើញថា តាមចម្លើយរបស់ទណ្ឌិតឈ្មោះ [redacted] រិត និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីនៅចំពោះមុខតុលាការកំពូលថា បណ្តឹងសាទុក្ខរបស់ខ្លួនធ្វើឡើងក្នុងគោលបំណងស្នើសុំឱ្យតុលាការកំពូលសម្រេចស្រូបទោសបញ្ចូលគ្នា ដោយសុំបន្ថយពី ៣ឆ្នាំ ៦ខែ មកនៅត្រឹម ២ឆ្នាំ ៦ខែ ដោយមូលហេតុខ្លួនទទួលទោសតាមសាលក្រមព្រហ្មទណ្ឌលេខ ៤០ “ឃ” ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ដែលមានកម្រិតទណ្ឌកម្ម ២ឆ្នាំ ដាក់ពន្ធនាគារពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ និង ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងសាលដីកាព្រហ្មទណ្ឌលេខ ២៧ ក្រV “វ” ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានកម្រិតទណ្ឌកម្ម ដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តែទោសនេះ អនុវត្តក្នុងពន្ធនាគារ ១ឆ្នាំ ៦ខែ សល់ពីនេះអនុវត្តទោសព្យួរធម្មតា ពីបទ រក្សាទុកចែកចាយ ប្រើប្រាស់ និងផ្តល់ទីតាំងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមមាត្រា ៤០, ៤៤ និង ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ការស្នើសុំនេះ តុលាការកំពូលពិនិត្យឃើញថា កម្រិតអតិបរមានៃទោសដែលត្រូវបានកំណត់ក្នុងមាត្រា ៤០, ៤៤ និង ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នេះមានអតិបរមានៃទោសគឺ ៥ឆ្នាំ ។ ដូច្នេះ ទោសដែលបានបូកបញ្ចូលគ្នា គឺពុំបានលើសពី ៥ឆ្នាំទេ គឺស្របតាមមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌហើយ ។ ដូច្នេះ សម្រាប់សាលក្រម និងសាលដីកាស្ថាពរ ទាំងពីរនេះ ទណ្ឌិតឈ្មោះ [redacted] រិត ត្រូវអនុវត្តទោសក្នុងពន្ធនាគារ សរុបចំនួន ៣ឆ្នាំ ៦ខែ ។ ហេតុដូច្នេះ ពាក្យសុំស្រូបទោសរបស់ទណ្ឌិតឈ្មោះ [redacted] រិត ពុំត្រឹមត្រូវតាមច្បាប់ទេ។

Scanned with CamScanner

៣-យល់ឃើញថា ពាក្យបណ្តឹងសាទុក្ខរបស់ទណ្ឌិតឈ្មោះ [redacted] រិត ពុំមានមូលហេតុតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១០៤ ក្រVII (ភស) ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## សម្រេច

១-បដិសេធបណ្តឹងសាទុក្ខលេខ ២៥៥ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] រិត ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១០៤ ក្រVII ភស ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ។

៣-សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ។

Scanned with CamScanner